**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣

ខិត្តប័ណ្ណព័ត៌មាន



*ខែតុលា ឆ្នាំ២០២៤*

ទិន្នន័យដែលបានយកមកបង្ហាញនៅក្នុងខិត្តបណ្ណព័ត៌មាននេះ គឺបានដកស្រង់ចេញពីរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ ដែលផលិតដោយវិទ្យាស្ថានជាតិស្ថិតិ (វ.ជ.ស) នៃក្រសួងផែនការ សហការជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក.ស.ក) ដោយមានការជួយគាំទ្របច្ចេកទេសពីអង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) ក្រោមវិសាលភាពគំនិតផ្តួចផ្តើមគម្រោង ៥០x២០៣០ ដើម្បីបញ្ចប់កង្វះខាតទិន្នន័យស្ថិតិកសិកម្ម។ គម្រោង ៥០x២០៣០ គឺជាគំនិតផ្តួចផ្តើមដែលបានអនុវត្តដែលមានម្ចាស់ជំនួយជាច្រើនតាមរយៈដៃគូតែមួយគត់រវាងធានាគារពិភពលោក (World Bank) អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និង មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម (IFAD) ដែលមានគោលបំណងតែមួយគត់កសាងសមត្ថភាពស្ថិតិជាតិ និងបង្កើតប្រព័ន្ធប្រមូលទិន្នន័យស្ថិតិកសិកម្មមួយប្រកបដោយប្រសិទ្ធភាព និងស្ថេរភាពយូរអង្វែង។

## ១. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រអង្កេត

ក្នុងអំឡុងខែធ្នូ ឆ្នាំ២០២៣ ស្ថាប័នពីរនៃរាជរដ្ឋាភិបាលកម្ពុជាចំនួនពីរ វ.ជ.ស និង ក.ស.ក បានអនុវត្តធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ បន្ទាប់ពីបានធ្វើអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ (CIAS ២០១៩) និងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ឆ្នាំ២០២១ ឆ្នាំ២០២២ រួចមក។ ការអង្កេតថ្នាក់ជាតិនេះបានប្រមូលព័ត៌មានស្តីពីការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ការធ្វើវារីវប្បកម្ម និងនេសាទ វិធីសាស្ត្រផលិតកម្ម និងបរិស្ថាន។

**រូបទី១៖ ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រអង្កេត**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

វិធីសាស្ត្រជ្រើសរើសសំណាកគំរូរបស់ CAS ២០២៣ ត្រូវបានធ្វើឡើងដោយផ្អែកលើសំណាកគំរូរបស់ CAS ២០២២ តាមវិធីសាស្ត្រស្ថិតិ។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ CAS ២០២៣ ត្រូវបានធ្វើឡើងផ្អែកលើការជ្រើសរើសសំណាកគំរូពីមណ្ឌលអង្កេត (EA) ជាតំណាងនៅទូទាំងប្រទេសកម្ពុជាពីក្របខ័ណ្ឌបញ្ជី (Frame) នៃជំរឿនទូទៅនៅប្រជាជនកម្ពុជាឆ្នាំ២០១៩។ គ្រួសារទាំងអស់នៅក្នុងមណ្ឌលអង្កេតដែលបានជ្រើសរើសរួច ត្រូវបានចុះបញ្ជីដើម្បីស្វែងរកគ្រួសារចូលរួមធ្វើសកម្មភាពកសិកម្ម។ ដោយប្រើប្រាស់ព័ត៌មានជាមូលដ្ឋាន គ្រួសារកាន់កាប់កសិកម្ម ត្រូវបានរកឃើញ ហើយបានរៀបចំ ជ្រើសរើសសំណាកគំរូតាមសកម្មភាពកសិកម្មនីមួយៗ ដើម្បីប្រមូលព័ត៌មានសំខាន់ៗបន្ថែមទៀត។

CAS ២០២៣ បានប្រើប្រាស់ម៉ាស៊ីនថេប្លេត (CAPI) ក្នុងការប្រមូលទិន្នន័យដោយផ្ទាល់ជាមួយអ្នកតបសម្ភាសន៍ ដើម្បីកត់ត្រា និងគ្រប់គ្រងទិន្នន័យ។



*ប្រភពរូបថត៖ វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០២៣*

ការធ្វើសម្ភាសន៍គ្រួសារកសិកម្មចាប់ផ្តើមពីថ្ងៃទី១១ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣។ សរុបមន្ត្រីទាំងអស់ដែលបានចូលរួមមានចំនួន ៤២៩នាក់ (រួមមានមន្ត្រីសម្ភាសន៍ចំនួន ៣៣៧ នាក់មន្ត្រីត្រួតពិនិត្យនៅមូលដ្ឋានចំនួន ៤៦ នាក់ និងមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យចំនួន ៤៦ នាក់) គ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១៥ ៧៥១ គ្រួសារបានបញ្ចប់សម្ភាសន៍។

ខិត្តប័ណ្ណព័ត៌មានស្ថិតិ នៃការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ នេះ គឺសម្រាប់តែការកាន់កាប់កសិកម្មគ្រួសារប៉ុណ្ណោះ។

## ២. គ្រួសារកាន់កាប់កសិកម្ម

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ ត្រូវបានប្រមាណថាគ្រួសារកាន់កាប់កសិកម្មមានចំនួនសរុប ១ ៨៦៣ ៨៣០ គ្រួសារ។ ផ្អែកតាមមូលដ្ឋានទិន្នន័យជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ ត្រូវបានប៉ាន់ប្រមាណថាមានចំនួនគ្រួសារសរុបចំនួន ៣ ៥៥៣ ០២១ គ្រួសារនៅទូទាំងប្រទេសកម្ពុជា ហើយដូច្នេះមានការប៉ាន់ប្រមាណ ៥២ ភាគរយ នៃចំនួនសរុប ត្រូវបានចូលរួមក្នុងផលិតកម្មកសិកម្ម។ គ្រួសារកាន់កាប់កសិកម្មទាំងនោះ ត្រូវបានចែកជាបួនតំបន់ភូមិសាស្ត្ររួមមាន៖ តំបន់វាលទំនាបមានគ្រួសារ

កាន់កាប់កសិកម្មច្រើនជាងគេមានដល់ទៅ ៤០ ភាគរយ បន្ទាប់មកគឺតំបន់បឹងទន្លេសាបមាន ៣៨ ភាគរយ  តំបន់ភ្នំ និងខ្ពង់រាបមាន ១៥ ភាគរយ និងចុងក្រោយតំបន់ឆ្នេរសមុទ្រមានតែ ៧ ភាគរយ។

រូបទី២ ៖ គ្រួសារកសិកម្មចែកតាមតាមតំបន់




រូបទី៣៖ ចំនួន និងភាគរយនៃគ្រួសារកសិកម្មចែកតាមតាមតំបន់ (គិតជាពាន់)




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

គ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា  បានរាយការណ៍ថាមានរហូតដល់ ៥៧ ភាគរយ ធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ ហើយមានតែ ៤៣ ភាគរយ ប៉ុណ្ណោះបានធ្វើកសិកម្ម ក្នុងគោលបំណងចម្បងសម្រាប់លក់។ បំណែងចែកតាមតំបន់មាន ៨២ ភាគរយ នៃគ្រួសារកសិកម្មនៅតំបន់ឆ្នេរសមុទ្របានធ្វើកសិកម្ម ក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ បន្ទាប់មកមាន ៦១ ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់ភ្នំនិងខ្ពង់រាប ហើយមាន ៥៦ ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់វាលទំនាប និងចុងក្រោយមាន ៥២ភាគរយ នៃគ្រួសារកសិកម្ម នៅតំបន់បឹងទន្លេសាប បានធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ។  គ្រួសារកាន់កាប់កសិកម្មក្នុងចំណោមគ្រួសារប្រមាណ ៦៦ ៦៧០ បានចូលរួមក្នុងសមាគមកសិករ (ប្រមាណ ៤ ភាគរយ)។

ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មប្រហែល ៣២ ភាគរយ ត្រូវបានរាយការណ៍ថាប្រហែលពាក់កណ្តាល នៃប្រាក់ចំណូលគ្រួសារសរុបចំនួន ៤០ ភាគរយ ទៅ ៦០ ភាគរយ ត្រូវបានរាប់បញ្ចូលជាប្រាក់ចំណូលពីការធ្វើកសិកម្មចំនួន ២៤ ភាគរយ បានរាយការណ៍មានចំនួនភាគច្រើនរហូតទៅដល់ ៦០ ភាគរយ ទៅដល់ ៩៩ ភាគរយនៃប្រាក់ចំណូលគ្រួសារសរុប  គឺត្រូវបានរាប់បញ្ចូលជាប្រាក់ចំណូលពីកសិកម្ម ចំនួន ៥ ភាគរយ ដែលបានរាយការណ៍ថាមានចំនួន ១០០ ភាគរយ នៃប្រាក់ចំណូលគ្រួសារសរុប ត្រូវបានគណនាថាជាប្រាក់ចំណូលពី វិស័យកសិកម្ម។

ប្រហែលមួយភាគបួន  នៃគ្រួសារកាន់កាប់កសិកម្មសរុបបានរាយការណ៍ថាមានចំនួន ២១ ភាគរយ នៃប្រាក់ចំណូលពីកសិកម្មដែលបានចូលរួមចំណែកតិចជាងប្រាក់ចំណូលគ្រួសារសរុបកាលពីឆ្នាំមុន។ ប្រាក់ចំណូលពីកសិកម្មចំនួន ៧០ ភាគរយ បានរាយការណ៍ថាបានចូលរួមចំណែកស្រដៀងគ្នា  ហើយប្រាក់ចំណូលចំនួន ៩ ភាគរយ ត្រូវបានរាយការណ៍ថាបានចូលរួមចំណែកច្រើនជាងប្រាក់ចំណូលគ្រួសារសរុបកាលពីឆ្នាំមុន។

រូបទី៤ ៖ ភាគរយនៃគ្រួសារកសិកម្មបានធ្វើកសិកម្ម ដើម្បីគោលបំណងចម្បងសម្រាប់ទុកប្រើប្រាស់ក្នុងគ្រួសារ និងចម្បងសម្រាប់លក់




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ៣. ផលិតកម្មដំណាំ

ការអង្កេតនេះបានប៉ាន់ប្រមាណថា  មានគ្រួសារកាន់កាប់កសិកម្មប្រមាណ ១ ៧៤២ ១០០ គ្រួសារ ស្មើនឹង ៩៣ ភាគរយ បានធ្វើសកម្មភាពដាំដំណាំ  ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១ ៨៦៣ ៨០០ គ្រួសារ។ ដំណាំជាច្រើនប្រភេទត្រូវបានរាយការណ៍ក្នុងអំឡុងពេលប្រមូលទិន្នន័យ  ប៉ុន្តែការអង្កេតរបស់យើង គឺផ្តោតទៅលើដំណាំចំនួនតែ៣០ មុខដំណាំប៉ុណ្ណោះដែលបានជ្រើសរើសថាជាដំណាំសំខាន់ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសួរព័ត៌មានលម្អិតដូចជា ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ការប្រើប្រាស់ (ជី ថ្នាំសម្លាប់សត្វល្អិត ប្រព័ន្ធស្រោចស្រព) និងបរិមាណផលបានទទួល។

ការអង្កេតនេះ  បានចាត់ចំណាត់ថ្នាក់ដំណាំចម្បង  ចំនួនបួនមុខដំណាំដែលគ្រួសារកសិកម្មបានដាំដុះច្រើនជាងគេ នៅក្នុងតំបន់ធំទាំងបួននៃប្រទេសកម្ពុជា។  ស្រូវធម្មតាត្រូវបានរកឃើញថាជាប្រភេទដំណាំដែលបានដាំច្រើនជាងគេបំផុត  នៅទូទាំងប្រទេស ហើយបានប្រើប្រាស់ផ្ទៃដីដាំដុះដំណាំស្រូវធម្មតានេះ មានសរុបចំនួន ២,០០ លាន ហិកតា និងផ្ទៃដីបានប្រមូលផលសរុបចំនួន

១,៩៥ លាន ហិកតា។ ទិន្នផលជាមធ្យមត្រូវបានរកឃើញថាមានចំនួន ៣ ១៤០ គីឡូក្នុងមួយហិកតា ខណៈដែលបរិមាណផលស្រូវធម្មតាសរុបទូទាំងប្រទេសមានចំនួនប្រមាណ ៦,១២ លាន តោន ។ ការអង្កេតនេះក៏បានបង្ហាញផងដែរថា នៅប្រទេសកម្ពុជាបានដាំដុះដំណាំហូបផ្លែជាច្រើនប្រភេទរួមមាន៖ ស្វាយ ចេក ទៀប ស្រកានាគ ទុរេន ត្របែក ខ្នុរ ព្រីង មៀន ទឹកដោះគោ ល្មុង និងម្នាស់។ នៅតំបន់វាលទំនាប និងតំបន់បឹងទន្លេសាប ដំណាំចេកជាដំណាំពេញនិយមជាងគេជាប់លំដាប់ទីពីរ។ ដូចគ្នាដែរនៅតំបន់វាលទំនាប និងតំបន់ភ្នំ និងខ្ពង់រាបវិញ ដំណាំចេកជាប់លំដាប់ទីពីរ ខណៈដែលដំណាំដូងជាប់លំដាប់ទីពីរផងដែរ នៅតំបន់ឆ្នេរសមុទ្រ។ នៅទូទាំងប្រទេស ផ្ទៃដីដាំដុះដំណាំចេកមានប្រមាណ ១៩ ០០០ ហិកតា និងផ្ទៃដីប្រមូលផលបានប្រមាណ ១២ ០០០ ហិកតា ជាមួយបរិមាណផលិតផលសរុប ៩៣ ០០០ តោន។ ផ្ទៃដីដាំដុះដំណាំស្វាយមានប្រមាណ ៦៩ ០០០ ហិកតា ដោយទទួលបរិមាណផលប្រហែល ៧១៨ ០០០តោន។ ផ្ទៃដីដាំដុះដំណាំដូងមានប្រមាណ ១០ ០០០ ហិកតា និងផ្ទៃដីប្រមូលផលបានប្រមាណ ១២១ ០០០ តោន និងផ្ទៃដីដាំស្វាយចន្ទីមានប្រមាណ ២៨៦ ០០០ ហិកតា ដោយទទួលបរិមាណផលប្រហែល ២០២ ០០០ តោន។

រូបទី៥ ៖ ដំណាំចម្បងបួនប្រភេទ ដែលបានដាំច្រើនជាងគេនៅក្នុងតំបន់នីមួយៗ (ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍)

តំបន់វាលទំនាប៖
៦៩២ ៤៣០ គ្រួសារ
១. ស្រូវធម្មតា
២. ចេក
៣. ស្វាយ
៤. ដូង

តំបន់បឹងទន្លេសាប៖
៦៦២ ៨៩០ គ្រួសារ
១. ស្រូវធម្មតា
២. ចេក
៣. ស្វាយ
៤. ដូង

១,៧៨២,១០០ គ្រួសារកាន់កាប់កសិកម្មបានធ្វើសកម្មភាពដាំដំណាំនៅទូទាំងប្រទេសកម្ពុជា

តំបន់ឆ្នេរសមុទ្រ៖
១១៣ ៦៨០ គ្រួសារ
១. ស្រូវធម្មតា
២. ដូង
៣. ចេក
៤. ស្វាយ

តំបន់ភ្នំ និងខ្ពង់រាប៖
២៧៣ ១១០ គ្រួសារ
១. ស្រូវធម្មតា
២. ស្វាយ
៣. ចេក
៤. ស្វាយចន្ទី

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

## ៤. សកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី

ការចិញ្ចឹមបសុសត្វ បសុបក្សីជាសកម្មភាពកសិកម្មដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា វាជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននិងផ្តល់ចំណូលដល់គ្រួសារកាន់កាប់កសិកម្មប្រមាណ ១ ៤០៤ ៥៥០ គ្រួសារ ស្មើនឹង ៧៥ ភាគរយ នៅក្នុងប្រទេស។ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបនៅតំបន់ឆ្នេរសមុទ្រ បានរាយការណ៍ថា មានភាគរយគ្រួសារចិញ្ចឹមបសុសត្វ និង/ឬបសុបក្សីច្រើនជាងគេប្រមាណជា ៨៧ ភាគរយ និងមានភាគរយទាបជាងគេគឺនៅតំបន់វាលទំនាបមានប្រមាណ ៧៣ ភាគរយ បានចិញ្ចឹមបសុសត្វ និង/ឬបសុបក្សី ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបនៅតំបន់នេះ។ តាមការប៉ាន់ប្រមាណនៅទូទាំងប្រទេសមាន គ្រួសារចិញ្ចឹមសុបក្សីចំនួន ១ ១២២ ៩៣០ គ្រួសារ និងគ្រួសារចិញ្ចឹមគោចំនួន ៦៩៥ ៦៤០ គ្រួសារ។

រូបទី៦ ៖ ចំនួនគ្រួសារកាន់កាប់កសិកម្ម ដែលបានរាយការណ៍ថាមានសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី បែងចែកតាមតំបន់ (គិតជាពាន់)




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

នៅតំបន់វាលទំនាប មានចំនួនគ្រួសារចិញ្ចឹមសត្វគោច្រើនជាងគេគឺប្រមាណ ៣០៥ ៣៤០ គ្រួសារ បន្ទាប់មកនៅតំបន់បឹងទន្លេសាបមានចំនួន ២៣៦ ៣២០ គ្រួសារ ហើយនៅតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១០០ ២៥០ គ្រួសារ និងតំបន់ឆ្នេរសមុទ្រ មានចំនួន ៥៣ ៧៤០ គ្រួសារ តិចជាងគេ។



*ប្រភពរូបថត៖ គ្រួសារចិញ្ចឹមគោនៅស្រុករលាប្អៀរខេត្តកំពង់ឆ្នាំង*

នៅតំបន់វាលទំនាប បានបង្ហាញថា មានចំនួនគ្រួសារចិញ្ចឹមបសុបក្សីច្រើនជាងគេ គឺចំនួន ៤៣៦ ៧៦០ គ្រួសារ បន្ទាប់មកគឺតំបន់បឹងទន្លេសាប មានគ្រួសារចំនួន ៤២១ ២៦០ គ្រួសារ ហើយនៅតំបន់ភ្នំ និងខ្ពង់រាប មានគ្រួសារចំនួន ១៦២ ៤០០ គ្រួសារ និងនៅតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារចិញ្ចឹមបសុបក្សីតិចជាងគេ គឺមានចំនួន ១០២ ១១០ គ្រួសារ។
តួលេខថ្នាក់ជាតិបានបង្ហាញថា ចំនួនសត្វគោជាមធ្យមក្នុង១គ្រួសារ មានចំនួន ៤,៦ ក្បាល ចំណែកបសុបក្សីមានចំនួន ២៦ ក្បាល ក្នុងមួយគ្រួសារកាន់កាប់កសិកម្ម។

## ៥. ការធ្វើសកម្មភាពវារីវប្បកម្ម និងនេសាទ

ការធ្វើវារីវប្បកម្ម ជាសកម្មភាពបំពេញចំណូលបន្ថែមក្នុងគ្រួសារកសិកម្មនៅប្រទេសកម្ពុជា តាមការប៉ាន់ប្រមាណមាន ៣ ភាគរយ នៃគ្រួសារកសិកម្មបានចូលរួមធ្វើសកម្មភាពវារីវប្បកម្ម ស្មើនឹងចំនួន ៦១ ៦៦០ គ្រួសារ។ ខណៈការនេសាទមានប្រមាណ ២៤ ភាគរយ ស្មើនឹងចំនួន ៤៤៤ ១៩០ គ្រួសារ។ ហើយមានគ្រួសារកសិកម្មបានចូលរួមធ្វើសកម្មភាពទាំងពីរ ធ្វើវារីវប្បកម្ម និងនេសាទគឺ មានចំនួន ១៦ ០២០ គ្រួសារ ស្មើនឹង ១ ភាគរយ នៃគ្រួសារកសិកម្មសរុប។
តំបន់ដែលមានចំនួនគ្រួសារច្រើនបំផុតធ្វើវារីវប្បកម្ម គឺនៅតំបន់វាលទំនាបមានចំនួន ៤៩ ០០០ គ្រួសារ ស្មើនឹង ៧ ភាគរយ នៃគ្រួសារកសិកម្មសរុប។ ចំណែកឯនៅតំបន់បឹងទន្លេសាបវិញគឺ មានគ្រួសារកសិកម្មធ្វើសកម្មភាពនេសាទច្រើនជាងគេបំផុត គឺចំនួន ១៩៩ ៣១០ គ្រួសារស្មើនឹង ២៨ ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មសរុប។

រូបទី៧ ៖ ចំនួនគ្រួសារកសិកម្មបានរាយការណ៍ថាមានសកម្មភាព វារីវប្បកម្ម និងឬនេសាទ ចែកតាមតំបន់




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣*

ក្នុងចំណោមគ្រួសារកសិកម្ម បានធ្វើសកម្មភាពនេសាទទាំងនោះ គឺមាន ៧៨ ភាគរយ បានរាយការណ៍ថានេសាទត្រី ហើយ ១៤ ភាគរយ បានរាយការណ៍ថានេសាទ/ចាប់ក្តាម និង ៦ ភាគរយ រាយការណ៍ពីការនេសាទ/រកខ្យង។ សម្រាប់បរិមាណផលសរុបដែលប្រមូលបានពីការនេសាទត្រីបានប្រមាណ ៣៥៧ លាន គីឡូក្រាម។



## ៦. ទំនាក់ទំនង

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការគ្នាធ្វើអង្កេត និងចេញរបាយការណ៍ចុងក្រោយអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ នៅក្នុងឆ្នាំ២០២៤។

| អង្កេតកសិកម្មកម្ពុជា | |
|---|---|
| អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) https://www.fao.org/cambodia/en/ | តំណាងអង្គការ FAO នៅប្រទេសកម្ពុជាមានអាស័យដ្ឋាននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ (MoP) https://www.nis.gov.kh/ | វិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការ (MoP) រាជរដ្ឋាភិបាលកម្ពុជា អគារ C, E និង F #៣៦៨ ព្រះមុនីវង្ស Blvd សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាធានីភ្នំពេញ ប្រទេសកម្ពុជា |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) https://web.maff.gov.kh/ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ២៥៥, ២០០ វិថីព្រះនរត្តម រាជធានីភ្នំពេញ Blvd (៤១) |

គាំទ្របច្ចេកទេសដោយ៖

Food and Agriculture Organization of the United Nations

គាំទ្រហិរញ្ញវត្ថុដោយ៖

50x2030 DATA-SMART AGRICULTURE